01346098

E404/9

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 11 / 2016
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម **យូរ ឧត្តារ** |
| កាលបរិច្ឆេទ: | ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៦ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចស្តីពីការទទួលយកឯកសារសិក្សាអំពីជើងឯកធ្វើជាឯកសារភស្តុតាង

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GIRAUD

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

## ១. សេចក្ដីផ្ដើម

១. នៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ មេធាវីការពារក្ដី នួន ជា បានផ្ញើអ៊ីម៉ែលមួយជូនដល់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង និង ភាគីទាំងអស់ ដោយស្នើឱ្យទទួលយកអត្ថបទមួយរបស់កាសែតភ្នំពេញប៉ុស្តិ៍ ("អត្ថបទ") ធ្វើជាឯកសារភ័ស្តុតាង ដើម្បីអាចប្រើប្រាស់ក្នុងការសួរដេញដោលចំពោះ តយ តេង (2-TCW-865)។ នៅថ្ងៃដដែល មុនពេលស្ដាប់សក្ខីកម្ម តយ តេង (2-TCW-865) អង្គជំនុំជម្រះបានស្ដាប់សេចក្ដីសន្និដ្ឋានផ្ទាល់មាត់របស់ភាគីពាក់ព័ន្ធនឹងសំណើនេះ។ បន្ថែមពីសំណើដំបូងរបស់ខ្លួន មេធាវីការពារក្ដី នួន ជា ក៏បានស្នើឱ្យអង្គជំនុំជម្រះទទួលយកធ្វើជាឯកសារភ័ស្តុតាងនូវសៀវភៅសិក្សាមួយក្បាលស្ដីពីអដ្ឋិធាតុរបស់មនុស្សដែលបានរកឃើញនៅជើងឯក ដែលបានយោងនៅក្នុងអត្ថបទនោះ ("សៀវភៅសិក្សាអំពីជើងឯក")[1]។ ភាគីដទៃទៀតពុំបានជំទាស់ទៅនឹងការទទួលយកអត្ថបទនេះធ្វើជាភ័ស្តុតាងនោះឡើយ ហើយសហព្រះរាជអាជ្ញាក៏បានគាំទ្រដល់សំណើសុំស្វែងរក និង ទទួលយកសៀវភៅសិក្សាអំពីជើងឯកនេះផងដែរ[2]។ អង្គជំនុំ-ជម្រះបានទទួលយកអត្ថបទនេះធ្វើជាឯកសារភ័ស្តុតាង ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង និង ឯកភាពលើសំណើសុំឱ្យព្យាយាមស្វែងរកសៀវភៅសិក្សាអំពីជើងឯក។ សេចក្ដីសម្រេចអំពីការទទួលយកសៀវភៅនេះធ្វើជាឯកសារភ័ស្តុតាងនឹងចេញនៅក្នុងពេលសមស្របខាងមុខ[3]។

២. នៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈស្នើឱ្យភាគីដាក់សេចក្ដីសន្និដ្ឋានទាក់ទិននឹងការទទួលយកជាឯកសារភ័ស្តុតាង នូវសៀវភៅសិក្សាអំពីជើងឯកមួយឈុតដែលមានចំនួន ៣២ លេខ ដោយពិចារណាទៅលើចំនួននៃសៀវភៅទាំងនេះ ដែលមានតែជាភាសាខ្មែរប៉ុណ្ណោះ។ អង្គជំនុំជម្រះក៏បានស្នើឱ្យភាគីដាក់សេចក្ដីសន្និដ្ឋានស្ដីពីភាពអាចទទួលយកបាននៃ "របាយការណ៍ស្ដីពីការវាយតម្លៃកម្មវិធីខាងក្រៅ" ដែលមានជាភាសាអង់គ្លេស និង ភាសា

---

[1] ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦, ទំព័រ ៦៣-៦៥ (ភាសាអង់គ្លេស)។ អង្គជំនុំជម្រះកត់សម្គាល់ថា សៀវភៅសិក្សាពីជើងឯកត្រូវបានគេជឿជាក់ពីដំបូងថាជា "របាយការណ៍កោសល្យវិច័យ" ដោយយោងតាមសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដី នួន ជា។

[2] ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦, ទំព័រ ៦៦-៦៨ (ភាសាអង់គ្លេស)។

[3] ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦, ទំព័រ ៧០-៧១ (ភាសាអង់គ្លេស)។

ខ្មែរ ដែលបានសង្ខេបអំពីលទ្ធផលនៃសៀវភៅសិក្សាអំពីជើងឯកនេះ ("ការវាយតម្លៃ")[4]។ នៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញា មេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន បានដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររៀងៗខ្លួន[5]។

៣. នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេច[6] ទទួលយកឯកសារនានាខាងក្រោមពាក់ព័ន្ធនឹងសៀវភៅសិក្សាអំពីជើងឯកធ្វើជាឯកសារភ័ស្តុតាង ដោយសំអាងហេតុជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចនេះនឹងចេញនៅក្នុងពេលវេលាដែលសមស្រប៖ i) ការវាយតម្លៃ[7] ii) សារម្មកថាដែលដូចគ្នាគ្រប់ក្បាលទាំងអស់នៃសៀវភៅសិក្សាពីជើងឯក ដែលបានស្នើដោយមេធាវីការពារក្តី នួន ជា[8] iii) ឧទាហរណ៍នៃការពិនិត្យលើការវិភាគអដ្ឋិធាតុ ដែលបានស្នើដោយមេធាវីការពារក្តី នួន ជា[9] iv) រូបថតឧបករណ៍ដែលបានរកឃើញនៅជើងឯក ដែលបានស្នើដោយសហព្រះរាជអាជ្ញា[10] និង v) តារាងសង្ខេបអំពីការរកឃើញអដ្ឋិធាតុមនុស្សដែលបានវិភាគនៅក្នុងសៀវភៅនីមួយៗ ដែលសហព្រះរាជអាជ្ញាបានស្នើ[11]។ អង្គជំនុំជម្រះក៏ឯកភាពតាមសំណើរបស់មេធាវីការពារក្តី នួន ជា ដែលស្នើសុំកោះហៅអ្នកជំនាញ 2-TCE-1062 (វឿន វុទ្ធី) ដើម្បីអនុញ្ញាតឲ្យភាគីនានាសាកសួរអំពីវិធីសាស្ត្រ និង ដំណើរការដែលបានអនុវត្តនៅក្នុងការរៀបចំ

---

[4] ការជូនដំណឹងអំពីការសិក្សាអដ្ឋិធាតុនៅជើងឯក និង ការក្រើនរម្លឹកទាក់ទងនឹងសំណើសុំនានា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានដាក់យឺត, ឯកសារ E404, ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦ ("ការជូនដំណឹង ឯកសារ E404")។

[5] សារណារបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងឯកសារគម្រោងជើងឯក, ឯកសារ E404/1, ជាមួយនឹងឧបសម្ព័ន្ធ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦ ("សារណារបស់សហព្រះរាជអាជ្ញា")។ សេចក្តីសង្កេតរបស់ នួន ជា អំពីការទទួលយកការសិក្សាអំពីអដ្ឋិធាតុនៅជើងឯក និង ការវាយតម្លៃខាងក្រៅ, ឯកសារ E404/2, ជាមួយនឹងឧបសម្ព័ន្ធ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦ ("សេចក្តីសន្និដ្ឋានរបស់ នួន ជា")។ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីលោក ខៀវ សំផន ស្តីពីការទទួលយកជាឯកសារភ័ស្តុតាងនូវរបាយការណ៍សិក្សា និង វាយតម្លៃអំពីជើងឯក, ឯកសារ E404/3, ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦ ("សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន")។

[6] សេចក្តីសម្រេចលើការទទួលយកជាឯកសារភ័ស្តុតាងនូវឯកសារសិក្សាពីជើងឯក, ឯកសារ E404/4, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦។

[7] ERN01235378-01235427 ភាសាអង់គ្លេស និង ERN01235428-01235506 ភាសាខ្មែរ។

[8] ឯកសារ E404/2.1.3។

[9] ឯកសារ E404/2.1.4។

[10] ឯកសារ E404/1.3។

[11] ឯកសារ E404/1.4។

សរសេរសៀវភៅសិក្សាអំពីជើងឯកនេះ[12]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះផ្តល់សំអាងហេតុសម្រាប់សេចក្តីសម្រេចរបស់ខ្លួនដូចតទៅ។

៤. អង្គជំនុំជម្រះកត់សម្គាល់ថា នៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានតែងតាំង 2-TCE-1062 (វឿន វុទ្ធី) ជាអ្នកជំនាញផ្នែកអដ្ឋិធាតុ ដែលអាចត្រូវបានសាកសួរលើគ្រប់បញ្ហាទាំងអស់ដែលគាត់មានចំណេះដឹង ឬ ជំនាញ ពាក់ព័ន្ធការសិក្សាស្តីពីជើងឯក និង សម្ភារៈពាក់ព័ន្ធ ព្រមទាំងបញ្ហានានាដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង០០២/០២[13]។

## ២. សារណា

៥. សហព្រះរាជអាជ្ញា បានលើកឡើងថាការទទួលយកការសិក្សាទាំងមូលធ្វើជាឯកសារភ័ស្តុតាងមិនមានភាពចាំបាច់នោះទេ ទោះជាយ៉ាងណាសៀវភៅសិក្សាអំពីជើងឯកចំនួន ៣៥ ទំព័រ និង ការវាយតម្លៃរបស់វានោះ គួរត្រូវទទួលយកធ្វើជាឯកសារភ័ស្តុតាង ដោយសារវាមានភាពពាក់ព័ន្ធគួរឱ្យជឿជាក់បាន មានយថាភាព ជួយដល់ការស្វែងរកការពិត ហើយវាពុំអាចរកបាននៅមុនពេលជំនុំជម្រះ[14]។ ជាពិសេស សហព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកធ្វើជាឯកសារភ័ស្តុតាងនូវឯកសារមានដូចជា៖ i) ការវាយតម្លៃ ii) តារាងសង្ខេបអំពីការរកឃើញនូវអដ្ឋិធាតុមនុស្សដែលបានវិភាគនៅក្នុងសៀវភៅនីមួយៗ ដែលសិក្សាពីជើងឯក សរុបមានចំនួន ៣២ ក្បាល[15] iii) រូបថតឧបករណ៍ផ្សេងៗដែលរកឃើញនៅកន្លែងកើតហេតុ និង ត្រូវបានចោទប្រកាន់ថា យកមកប្រើដើម្បីសម្លាប់ ឬ ទប់ទល់នឹងជនរងគ្រោះ[16] និង iv) ការវិភាគអដ្ឋិធាតុអំពីលលាដ៍ក្បាលចំនួនមួយទំព័រ ជាតំណាងឱ្យព័ត៌មានដែលមាននៅក្នុងសៀវភៅសិក្សាពីជើងឯក[17]។ សហព្រះរាជអាជ្ញាបានអះអាងថា ឯកសារទាំងនេះមានភាពពាក់ព័ន្ធ ដោយសារវាទាក់ទិននឹងការសម្លាប់នៅជើងឯក និងទីតាំងកប់សាកសពដែលជាផ្នែកនៃការចោទប្រកាន់នានានៅក្នុងសំណុំរឿង ០០២/០២ ដែល

---

[12] ឯកសារ E404/4 កថាខណ្ឌ ៧។

[13] សេចក្តីសម្រេចស្តីពីការតែងតាំងអ្នកជំនាញ 2-TCE-1062, ឯកសារ E404/8 ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៦។

[14] សារណារបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១, ១០, ២៥។

[15] សារណារបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៧, ២៦, ឯកសារ E404/1.4។

[16] សារណារបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៥, ២៦, ឯកសារ E404/1.3។

[17] សារណារបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣, ឯកសារ E404/1.2។

ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១[18]។ ឯកសារទាំងនេះក៏ជាប់ពាក់ព័ន្ធដោយផ្ទាល់នឹងភស្តុតាងដទៃទៀត ដែលមាននៅក្នុងសំណុំរឿងរួចមកហើយ ជាពិសេស អត្ថបទ និង សក្ខីកម្មពាក់ព័ន្ធរបស់ តយ តេង (2-TCW-865) និង ហ៊ឹម ហ៊ុយ (2-TCW-906)[19]។ ចុងក្រោយ សហព្រះរាជអាជ្ញាបានលើកឡើងថា ការវាយតម្លៃ និង សៀវភៅសិក្សាអំពីជើងឯក ត្រូវបានបោះពុម្ពផ្សាយនៅក្រោយការចាប់ផ្តើមជំនុំជម្រះ ហើយថាឯកសារទាំងនេះមានយថាភាព និង គួរឱ្យជឿជាក់បាន ដោយសារតែឯកសារទាំងនេះ ត្រូវបានរៀបចំឡើងដោយអ្នកជំនាញដែលមានគុណវុឌ្ឍិ[20]។

៦. មេធាវីការពារក្តី នួន ជា ជំទាស់ទៅនឹងការទទួលយកសៀវភៅសិក្សាអំពីជើងឯកធ្វើជាឯកសារភស្តុតាង ដោយសារសៀវភៅនេះមិនបានបំពេញលក្ខខណ្ឌតម្រូវនៃភាពពាក់ព័ន្ធ និង ភាពគួរឱ្យជឿជាក់បាន ដែលបានកំណត់នៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ ទោះបីជាមេធាវីការពារក្តី នួន ជា កម្រិតការពិនិត្យរបស់ខ្លួនលើសៀវភៅសិក្សាអំពីជើងឯក ត្រឹមតែអារម្ភកថារបស់សៀវភៅដែលបានសរសេរដូចគ្នាគ្រប់លេខទាំងអស់ និង របាយការណ៍ពិនិត្យឆ្អឹងលលាដ៍ក្បាលនីមួយៗក្តី[21] មេធាវីការពារក្តីបានអះអាងថាការសិក្សានេះមានភាពជាប់ពាក់ព័ន្ធតិចតួច[22]។ មេធាវីការពារក្តី នួន ជា ជំទាស់ទៅនឹងសៀវភៅសិក្សាពីជើងឯក ថាវាមិនមែនជា "ការសិក្សាបែបកោសល្យវិច័យដើម្បីកិច្ចនីតិវិធីផ្លូវច្បាប់" នោះឡើយ ហើយជំហានទី៣នៃការសិក្សានេះ នៅ"កំពុងតែដំណើរការ" នៅឡើយ[23]។ លើសពីនេះទៀត មេធាវីការពារក្តី នួន ជា បានលើកឡើងថា សៀវភៅសិក្សាពីជើងឯកមិនគួរឱ្យជឿជាក់បានឡើយបើ*តាមការពិនិត្យបឋម* ដោយសារតែកង្វះព័ត៌មានពាក់ព័ន្ធនឹងវិធីសាស្រ្តដែលបានប្រើប្រាស់ និង ដំណើរការនៃការរក្សាឆ្អឹងលលាដ៍ក្បាល និង អដ្ឋិធាតុ ព្រមទាំងភាពខ្វះនូវយុត្តិកម្មបែបវិទ្យាសាស្រ្តសម្រាប់លទ្ធផលនៃការរកឃើញមួយចំនួន[24]។ ចំពោះការវាយតម្លៃ មេធាវីការពារក្តី នួន ជា អះអាងថា ទោះបីជាការវាយតម្លៃនេះមានសញ្ញាណនៃភាពអាចជឿជាក់បាន និង យថាភាពនៃ*ការបញ្ជាក់បឋម* ក៏ដោយ ក៏វាមិនគួរត្រូវបានទទួលយកធ្វើជាឯកសារភ

[18] សារណារបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៩។

[19] សារណារបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៩-២០។

[20] សារណារបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២១-២៤។

[21] សេចក្តីសន្និដ្ឋានរបស់ នួន ជា, កថាខណ្ឌ ៨។ សូមមើល ឯកសារ E404/2.1.3 និង E404/2.1.4។

[22] សេចក្តីសន្និដ្ឋានរបស់ នួន ជា, កថាខណ្ឌ ១៤។

[23] សេចក្តីសន្និដ្ឋានរបស់ នួន ជា, កថាខណ្ឌ ១៣។

[24] សេចក្តីសន្និដ្ឋានរបស់ នួន ជា, កថាខណ្ឌ ១៥-១៧។

ស្តុតាងនោះឡើយ ព្រោះវាជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងសៀវភៅសិក្សាអំពីជើងឯក[25]។ ចំពោះជម្រើសផ្សេងទៀត ប្រសិនបើអង្គជំនុំជម្រះទទួលយកសៀវភៅសិក្សាពីជើងឯកជាឯកសារភស្តុតាង មេធាវីការពារក្តី នួន ជា ស្នើសុំឱ្យទទួលយកការវាយតម្លៃជាឯកសារភស្តុតាង និង កោះហៅអ្នកជំនាញ 2-TCE-1062 (វឿន វុទ្ធី) ឱ្យមកផ្តល់សក្ខីកម្មផងដែរ[26]។

៧. មេធាវីការពារក្តី ខៀវ សំផន លើកឡើងថា សៀវភៅសិក្សាអំពីជើងឯក មិនគួរទទួលយកជាភស្តុតាងនោះឡើយ ព្រោះសៀវភៅសិក្សានេះវែង និង មានលក្ខណៈស្មុគស្មាញ ដែលធ្វើឱ្យកិច្ចដំណើរការនីតិវិធីតាមផ្លូវច្បាប់ជាក់ស្តែងមិនអាចធ្វើទៅបាន ហើយខ្លួនមិនរំពឹងថាការសិក្សានេះនឹងត្រូវបានបកប្រែទាំងស្រុងនោះឡើយ។ មេធាវីការពារក្តី ខៀវ សំផន បានអះអាងទៀតថា ខ្លួនមិនជំទាស់នឹងការទទួលយកការវាយតម្លៃនេះធ្វើជាឯកសារភស្តុតាងនោះឡើយ[27]។

## ៣. ច្បាប់ជាធរមាន

៨. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនៃនីតិវិធីទាំងអស់ អង្គជំនុំជម្រះអាចទទួលយកនូវភស្តុតាងទាំងឡាយណា ដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត នៅពេលដែលភស្តុតាងនោះក៏បំពេញផងដែរនូវបទដ្ឋាន *ការបញ្ជាក់បឋម* នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និង យថាភាព ដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះនឹងសម្រេចលើសំណើសុំឱ្យទទួលយកភស្តុតាងថ្មីស្របតាមលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក៏តម្រូវផងដែរថា ភាគីដែលស្នើសុំឱ្យទទួលយកភស្តុតាងថ្មី ត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថាភស្តុតាងដែលខ្លួនបានស្នើសុំដាក់នោះ មិនអាចរកបាននៅមុនពេលចាប់ផ្តើមការជំនុំជម្រះ ឬ មិនអាចត្រូវបានរកឃើញ ទោះបីជាបានខិតខំព្យាយាមយ៉ាងសមស្របហើយក៏ដោយ[28]។ ទោះបីជា

---

[25] សេចក្តីសន្និដ្ឋានរបស់ នួន ជា, កថាខណ្ឌ ២២។

[26] សេចក្តីសន្និដ្ឋានរបស់ នួន ជា, កថាខណ្ឌ ២៤។

[27] សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន។

[28] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងភាគពីរកិច្ចដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា ឯកសារ E363/3, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥, កថាខណ្ឌ ២៨-២៩។

យ៉ាងណាក៏ដោយ នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះបានទទួលយកភ័ស្តុតាងនានា ដែលពុំបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនេះឡើយ រួមទាំងក្នុងករណីដែលភ័ស្តុតាងពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងសម្ភារៈដែលមានរួចហើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និង ក្នុងករណីដែលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យមានការវាយតម្លៃប្រភពទាំងនេះរួមគ្នា និង ករណីដែលឯកសារដែលបានស្នើសុំដាក់នេះ គឺជាភ័ស្តុតាងដោះបន្ទុក ដែលតម្រូវឱ្យមានការវាយតម្លៃដើម្បីជៀសវាងកំហុសក្នុងការស្វែងរកយុត្តិធម៌[29]។

## ៤. សំអាងហេតុ

៩. អង្គជំនុំជម្រះកត់សម្គាល់ថា សៀវភៅសិក្សាអំពីជើងឯក និង ការវាយតម្លៃលើការសិក្សានេះ មានព័ត៌មានពាក់ព័ន្ធនឹងចំនួន អាយុ ភេទ និង ភ័ស្តុតាងដែលជាស្លាកស្នាមពីការធ្វើទារុណកម្មចំពោះអ្នកជាប់ឃុំដែលត្រូវបានសម្លាប់នៅជើងឯក[30]។ អង្គជំនុំជម្រះយល់ឃើញថាទាំងសៀវភៅសិក្សាអំពីជើងឯក និង ការវាយតម្លៃ មានភាពជាប់ពាក់ព័ន្ធ និង ទាក់ទិនយ៉ាងជិតស្និទ្ធទៅនឹងសម្ភារៈដទៃទៀតដែលមានរួចហើយនៅក្នុងសំណុំរឿង ជាពិសេស អត្ថបទ និង សក្ខីកម្មពាក់ព័ន្ធរបស់ តយ តេង (2-TCW-865) និង ហ៊ឹម ហ៊ុយ (2-TCW-906)។ ទោះបីជាមេធាវីការពារក្តី នួន ជា ជំទាស់ទៅនឹងការទទួលយកជាឯកសារភ័ស្តុតាងនូវសៀវភៅសិក្សាអំពីជើងឯក និង ការវាយតម្លៃនេះក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្តីបានទទួលស្គាល់ថា "កម្មវត្ថុនៃការសិក្សានេះជាប់ពាក់ព័ន្ធនឹងសំណុំរឿងបច្ចុប្បន្ន ដោយសារវាទាក់ទងនឹងការចោទប្រកាន់អំពីការសម្លាប់នៅជើងឯក" និង ទាក់ទងនឹង "ភ័ស្តុតាងនៅក្នុងសំណុំរឿង"[31]។ ស្រដៀងគ្នានេះផងដែរ មេធាវីការពារក្តី នួន ជា បានទទួលស្គាល់ពីភាពជាប់ពាក់ព័ន្ធនៃសៀវភៅសិក្សាអំពីជើងឯកនៅក្នុងសេចក្តី

[29] សេចក្តីសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) សុំឱ្យទទួលយកឯកសារចំនួន ២៩ ទាក់ទងនឹងសក្ខីកម្មរបស់អ្នកជំនាញ 2-TCE-95, ឯកសារ E367/8, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៦, កថាខណ្ឌ ១១។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ នួន ជា និង ខៀវ សំផន (E236/4/1, E265, E271, E276, E276/1), ឯកសារ E276/2, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣, កថាខណ្ឌ ២។

[30] ការវាយតម្លៃ ត្រង់ ERN 01235454-01235456 ភាសាខ្មែរ។

[31] សេចក្តីសន្និដ្ឋានរបស់ នួន ជា, កថាខណ្ឌ ១២។

សន្និដ្ឋានដោយផ្ទាល់មាត់របស់ខ្លួនស្ដីអំពីអត្ថបទនេះ ដោយបានបញ្ជាក់ថា"របាយការណ៍កោសល្យវិច័យដែលខ្លួនយោងនោះ បានចូលរួមចំណែកមួយក្នុងការស្វែងរកការពិត"[32]។

១០. អង្គជំនុំជម្រះ យល់ឃើញផងដែរថា ទាំងសៀវភៅសិក្សាពីជើងឯក និង ការវាយតម្លៃ ត្រូវបានបង្កើតឡើងដោយប្រភពនានាដែលគួរឱ្យជឿជាក់បាន។ សៀវភៅសិក្សាអំពីជើងឯកត្រូវបានរៀបចំធ្វើឡើងក្រោមការដឹកនាំរបស់ 2-TCE-1062 (វឿន វុទ្ធី)[33] ដែលនឹងត្រូវកោះហៅឱ្យមកផ្ដល់សក្ខីកម្មក្នុងឋានៈជាអ្នកជំនាញនៅក្នុងសំណុំរឿង ០០២/០២។ ការវាយតម្លៃនេះត្រូវបានរៀបចំឡើងដោយលោកស្រីបណ្ឌិត Nancy BEAVAN ដែលមានសញ្ញាបត្រថ្នាក់បណ្ឌិតជំនាញផ្នែកវិភាគបណ្ដុំសារធាតុគីមី អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រវិភាគ និង វាយតម្លៃ និងបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រភូមិសាស្ត្រ[34]។ ក្រៅពីសញ្ញាប័ត្រសិក្សាទាំងអស់នេះ លោកស្រីបណ្ឌិត BEAVAN មានបទពិសោធន៍ធ្វើការងារយ៉ាងច្រើន រួមមាន ការត្រួតពិនិត្យកម្មវិធី និង ការគ្រប់គ្រងគម្រោង[35]។ អង្គជំនុំជម្រះកត់សម្គាល់ថា មេធាវីការពារក្ដី ខៀវ សំផន ពុំជំទាស់ទៅនឹងការទទួលយកការវាយតម្លៃធ្វើជាសេចក្ដីសង្ខេបនៃលទ្ធផលនៃការសិក្សាអំពីជើងឯកនោះឡើយ[36]។ ទន្ទឹមនឹងនោះផងដែរ មេធាវីការពារក្ដី នួន ជា ពុំជំទាស់ទៅនឹងការទទួលយកការវាយតម្លៃជាឯកសារភ័ស្ដុតាងនោះឡើយ ប្រសិនបើអង្គជំនុំជម្រះសម្រេចទទួលយកសៀវភៅសិក្សាអំពីជើងឯកនោះ[37]។ ជាក់ស្ដែង មេធាវីការពារក្ដី នួន ជា បានទទួលស្គាល់ថាការវាយតម្លៃនេះ "ត្រូវបានរៀបចំឡើងដោយបុគ្គលម្នាក់ដែលមានបទពិសោធន៍វាយតម្លៃលើគម្រោងនានា ហើយវិធីសាស្ត្រដែលបានប្រើប្រាស់ដើម្បីវាយតម្លៃការសិក្សានេះ បានបង្ហាញយ៉ាងច្បាស់ ហេតុនេះ វាបំពេញផងដែរនូវបទដ្ឋាន *ការបញ្ជាក់បឋម*នៃភាពអាចជឿជាក់បាន និង យថាភាព"[38]។ ការវាយតម្លៃសន្និដ្ឋានថា សៀវភៅសិក្សាអំពី

---

[32] ប្រតិចារឹកសវនាការ, ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦, ទំព័រ ៦៤ (ភាសាអង់គ្លេស)។

[33] ការវាយតម្លៃ ត្រង់ ERN 01235455 ភាសាខ្មែរ។

[34] ការវាយតម្លៃ ត្រង់ ERN 01235457 ភាសាខ្មែរ។

[35] ការវាយតម្លៃ ត្រង់ ERN 01235457 ភាសាខ្មែរ។

[36] សេចក្ដីសន្និដ្ឋានរបស់ ខៀវ សំផន។

[37] សេចក្ដីសន្និដ្ឋានរបស់ នួន ជា, កថាខណ្ឌ ២២។

[38] សេចក្ដីសន្និដ្ឋានរបស់ នួន ជា, កថាខណ្ឌ ២២។

ជើងឯក គឺជាគម្រោងមួយដ៏ជោគជ័យ និង ប្រកបដោយប្រសិទ្ធភាព[39] ដែលបន្ថែមទៅលើភាពអាចជឿជាក់បាននៃសៀវភៅសិក្សាអំពីជើងឯកនេះ។

១១. ចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ទៅលើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា និង មេធាវីការពារក្តី ខៀវ សំផន ដែលថាការប្រើប្រាស់សំណៅនៃសៀវភៅសិក្សាអំពីជើងឯកទាំងមូលពុំមានភាពចាំបាច់នៅក្នុងកិច្ចដំណើរការនីតិវិធី ព្រមជាមួយមូលហេតុទាក់ទិននឹងការបកប្រែផងដែរ។ ទោះបីជាឯកសារនេះមានភាពជាប់ពាក់ព័ន្ធ គួរឲ្យជឿជាក់បាន និង មានយថាភាព អង្គជំនុំជម្រះយល់ឃើញថា ការទទួលយកធ្វើជាឯកសារភស្តុតាងនូវសៀវភៅសិក្សាអំពីជើងឯកទាំងមូល មិនអាចធ្វើបាននោះឡើយនៅក្នុងដំណាក់កាលចុងបញ្ចប់សំណុំរឿងនេះ ដោយសារតែសៀវភៅសិក្សាអំពីជើងឯកនេះមានចំនួនច្រើនក្បាល មានលក្ខណៈស្មុគស្មាញ និង មានតែជាភាសាខ្មែរប៉ុណ្ណោះ។ ហេតុនេះ អង្គជំនុំជម្រះទទួលយកជាឯកសារភស្តុតាងតែចំពោះការវាយតម្លៃ និង ឯកសារដទៃទៀតដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌ ៣ នៃសេចក្តីសម្រេចនេះប៉ុណ្ណោះ។ អង្គជំនុំជម្រះយល់ឃើញថា ការទទួលយកឯកសារទាំងនេះនឹងធ្វើឲ្យការវាយតម្លៃភស្តុតាងទាក់ទិននឹងជើងឯកកាន់តែមានភាពពេញលេញ និង ជាប្រយោជន៍ដល់ការស្វែងរកការពិត។

**តាមសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេច៖**

**ទទួលយក** ឯកសារខាងក្រោមនេះធ្វើជាឯកសារភស្តុតាង៖

ក. ការវាយតម្លៃ និង ដាក់លេខ E3/10643 សម្រាប់ឯកសារនេះ។

ខ. អារម្ភកថាដែលដូចៗគ្នាគ្រប់ក្បាលទាំងអស់នៃសៀវភៅសិក្សាពីជើងឯកដែលមេធាវីការពារក្តី នួន ជា បានស្នើ និង ដាក់លេខ E3/10645 សម្រាប់ឯកសារនេះ។

គ. ឧទាហរណ៍នៃការពិនិត្យលើការវិភាគអដ្ឋិធាតុ ដែលមេធាវីការពារក្តី នួន ជា បានស្នើ និង ដាក់លេខយោងជាឯកសារ E3/10646។

ឃ. រូបថតឧបករណ៍ដែលបានរកឃើញនៅជើងឯក ដែលសហព្រះរាជអាជ្ញា បានស្នើ និង ដាក់លេខ E3/10647 សម្រាប់រូបថតទាំងនេះ។ និង

[39] ការវាយតម្លៃ ត្រង់ ERN 01235503 ភាសាខ្មែរ។

ង. តារាងសង្ខេបស្តីពីការរកឃើញនូវអដ្ឋិធាតុមនុស្សដែលបានវិភាគនៅក្នុងសៀវភៅនីមួយៗ ដែលសហព្រះរាជអាជ្ញាបានស្នើ និងដាក់លេខ E3/10648 សម្រាប់ឯកសារនេះ។

ភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**